ASEAN CENTRE FOR BIODIVERSITY

german cooperation
DEUTSCHE ZUSAMMENARBEIT

Implemented by

giz

GFA CONSULTING GROUP




# សៀវភៅ
# អនុផលព្រៃឈើមានតម្លៃសេដ្ឋកិច្ច
# នៅភ្នំគូលែន







# មាតិកា


សេចក្តីថ្លែងអំណរគុណ ........................................................................ 1

សេចក្តីផ្តើម ....................................................................................... 2

ឫស្សីឃ្លៃ ( *Bambusa bambos* ) ......................................................... 5

វល្លិ៍ទ្បែទ្បូ ( *Lygodium salicifolium* ) ..................................................... 7

ក្រកោ ( *Amomum ovoideum* ) .......................................................... 9

ខាន់ម៉ា ( *Ancistrocladus tectorius* ) .................................................... 11

កុមារពេជ្យ ( *Stephania rotunba* Lour ) ............................................... 13

គុយ ( *Willughbeia edulis* ) ................................................................ 15

វល្លិ៍ធ្លក ( *Secamone lagenifera* ) ........................................................ 17

រំចេកស្រុក ( *Pandanus humilis* ) ......................................................... 19

ផ្តៅក្រែក ( *Calamus viminalis* ) .......................................................... 21

ផ្តៅឈ្វាំង ( *Calamus palustris* ) ......................................................... 23

ផ្តៅសោម ( *Daemonorops jenkinsiana* ) ................................................ 25

ផ្តៅដំបង ( *Calamus rudentum* ) .......................................................... 27

សែសឹង ( *Calamus tetradactylus* ) ....................................................... 29

ចង្អូរ ( *Plectocomia pierreana* ) ........................................................... 31

ត្រាច ( *Dipterocarpus intricatus* ) ....................................................... 33

ក្រពុលបាយ ( *Litsea glutinosa* ) .......................................................... 35

រំដួល (*Melodorum fruticosum*)........................................................ 37

កប្ង៉ូរ (*Cinnamomum camphora*) ........................................................ 39

ស្ដៅ (*Azadirachta indica*).................................................................. 41

ផ្ចឹក (*Shorea obtuse*)......................................................................... 43

ឈើទាលទឹក (*Dipterocarpus alatus*)................................................... 45

គូលែន (*Litchi chinensis*).................................................................... 47

អន្ទង់-ស (*Eurycoma longifolia*) ........................................................ 49

មើមថ្នាំចិន (*Smilax glabra*) .............................................................. 51

ចន្ទន៍ក្រស្នា (*Aquilaria crassna*)........................................................ 53

ឯកសារយោង........................................................................................ 54

## សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់នាយកដ្ឋានជីវៈចម្រុះ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថាន ដែលបានសម្របសម្រួល និងផ្តួចផ្តើមឱ្យមានគម្រោងក្នុងការសិក្សាស្រាវជ្រាវពីធនធានជីវៈចម្រុះដែលមានតម្លៃសេដ្ឋកិច្ច នៅឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម "ភ្នំគូលែន" ក្នុងគោលបំណងកត់ត្រានូវប្រភេទអនុផលព្រៃឈើ ឬផលិតផលពីជីវៈចម្រុះនៅក្នុងតំបន់ និងសក្តានុពលនៃការប្រើប្រាស់ និងតម្លៃសេដ្ឋកិច្ចរបស់ប្រភេទទាំងនោះ ដើម្បីជម្រុញនិងធ្វើឱ្យប្រសើរឡើងនូវខ្សែសង្វាក់តម្លៃ ជាពិសេសធ្វើយ៉ាងណាឱ្យមានការអភិរក្សជីវៈចម្រុះ និងជីវភាពប្រជាសហគមន៍បានប្រសើរឡើង។

សូមអរគុណជាពិសេសដល់អង្គការ GIZ ដែលបានផ្តល់មូលនិធិតាមរយៈ GFA Consulting Group ដល់ការអនុវត្តគម្រោងការសិក្សាជ្រាវ និងចងក្រងឯកសារនេះឡើងសម្រាប់ជាប្រយោជន៍ដល់សារធារណជនឱ្យបានស្គាល់ពីប្រភេទអនុផលព្រៃឈើមានតម្លៃសេដ្ឋកិច្ចនៅ ភ្នំគូលែន និងជាឯកសារមូលដ្ឋានសម្រាប់ប្រជាសហគមន៍ដែលរស់នៅក្នុងតំបន់ឧទ្យានជាតិភ្នំគូលែន ក៏ដូចជាអ្នកដែលរស់នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិផ្សេងទៀតឱ្យបានដឹងពីប្រភេទអនុផលព្រៃឈើដែលមានតម្លៃសេដ្ឋកិច្ច ដែលអាចជួយឱ្យជីវភាពរបស់ពួកគាត់បានកាន់តែប្រសើរឡើង។

សូមថ្លែងនូវការអរគុណផងដែរដល់ មន្ទីរបរិស្ថានខេត្តសៀមរាបដែលបានជួយសម្របសម្រួលដល់ក្រុមសិក្សាក្នុងការធ្វើការសម្ភាសន៍ ការចុះទៅក្នុងព្រៃផ្ទាល់ និងរៀបចំប្រជុំជាមួយប្រជាសហគមន៍។

យើងក៏សូមអរគុណផងដែរដល់ក្រុមអ្នកបច្ចេកទេសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងអាជ្ញាធរព្រះវិហារ ដែលបានចូលរួមពិនិត្យ និងផ្ទៀងផ្ទាត់ទៅលើលក្ខណៈបច្ចេកទេស និងខ្លឹមសារអត្ថបទរបស់ប្រភេទនីមួយៗ។

## សេចក្ដីផ្ដើម

បច្ចុប្បន្នប្រទេសកម្ពុជាមានតំបន់ការពារធម្មជាតិចំនួនជាង ៥០កន្លែង ដែលគ្របដណ្ដប់លើផ្ទៃដីជាង ៧,៥លានហិចតា ឬស្មើនឹងជិត ៤១% នៃផ្ទៃប្រទេសទាំងមូល។ ហើយប្រទេសកម្ពុជាបានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសនានាលើពិភពលោកដែលមានភាគរយផ្ទៃដីតំបន់ការពារធម្មជាតិខ្ពស់ជាងគេ។ តំបន់ការពារធម្មជាតិនៅកម្ពុជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ជីវៈចម្រុះថ្នាក់ជាតិ ថ្នាក់តំបន់ និងពិភពលោក។ តាមការប៉ាន់ស្មាន ៤០% នៃសេដ្ឋកិច្ចពិភពលោក និង ៨០% នៃសេចក្ដីត្រូវការរបស់អ្នកក្រីក្រ គឺបានមកពីធនធានជីវៈចម្រុះ ហើយជីវៈចម្រុះនេះទៀតសោតក៏ចូលរួមក្នុងការបង្កើនភាពធន់ទ្រាំនឹងបញ្ហាប្រឈមមួយចំនួនរបស់ពិភពលោក ពិសេសការប្រែប្រួលអាកាសធាតុ។ ក្រៅពីនេះ តំបន់ការពារធម្មជាតិក៏បានផ្ដល់នូវផលិតផលធម្មជាតិ និងសេវាកម្មចម្រុះយ៉ាងសម្បូរបែបដល់សហគមន៍ជនបទដែលពឹងផ្អែកលើធនធានព្រៃឈើដូចជា៖ ប្រូតេអ៊ីន ឱសថ ជម្រក និងអនុផលព្រៃឈើ។

ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម ″ភ្នំគូលែន″ ជាតំបន់ការពារធម្មជាតិមួយរបស់ប្រទេសកម្ពុជាដែលបានកំណត់ដោយព្រះរាជក្រឹត្យនៅឆ្នាំ១៩៩៣ លើផ្ទៃដី ៣៧,៣៧៥ហិចតា គ្របដណ្ដប់ដោយស្រុកចំនួនបីនៃខេត្តសៀមរាប គឺស្រុកស្វាយលើ ស្រុកបន្ទាយស្រី និងស្រុកវ៉ារិន។ ប្រជាជនកម្ពុជាបានចាត់ទុកភ្នំគូលែន ជាភ្នំសក្តិសិទ្ធជាងគេនៅកម្ពុជា និងជាកន្លែងពេញនិយមសម្រាប់ការគោរពបូជា និងការលំហែរនៅពេលចុងសប្ដាហ៍ និងនៅពេលបុណ្យម្ដងៗ។ ឧទ្យានជាតិភ្នំគូលែនត្រូវបានចាត់ទុកជាតំបន់មានតម្លៃខ្ពស់សម្រាប់ការអភិរក្ស ដោយផ្អែកលើទិដ្ឋភាពចម្បងៗចំនួនបី គឺ៖ ភាពសម្បូរបែបនៃជីវៈចម្រុះ សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងមុខងារសង្គម។

តាមការសិក្សាបានបង្ហាញថា ឧទ្យានជាតិភ្នំគូលែនមានរុក្ខជាតិចំនួន ៧៧៩ប្រភេទ សត្វស្លាប ១៩៨ប្រភេទ ល្មូន៦០ប្រភេទ ថលជលិក២៥ប្រភេទ និងចំនួនប្រចៀវ២៥ប្រភេទ។ អ្វីដែលកាន់តែពិសេសសម្រាប់ឧទ្យានជាតិភ្នំគូលែន គឺការសិក្សាថ្មីៗបានបង្ហាញថាក្នុងចំណោមរុក្ខជាតិទាំង ៧៧៩ប្រភេទ គឺមានចំនួន ២៨ប្រភេទ ស្ថិតនៅក្នុងបញ្ជីក្រហមស្ដីពីប្រភេទរងការគម្រាមកំហែងរបស់អង្គការសហភាពអន្តរជាតិដើម្បីអភិរក្សធម្មជាតិ និងធនធានធម្មជាតិ (IUCN)។

សេវាកម្មប្រព័ន្ធអេកូឡូស៊ីសំខាន់ៗនៅឧទ្យានជាតិភ្នំគូលែនរួមមាន៖ ថ្មភក់ ព្រៃឈើ និងប្រភពទឹកដ៏សំខាន់មួយសម្រាប់ខេត្តសៀមរាប ជាពិសេសសេវារក្សាប្រភពទឹកក្រោមដីដែលជាអ្នករក្សាស្ថិរភាពគ្រឹះប្រាសាទនានាក្នុងតំបន់អង្គរ។ យោងតាមការសិក្សា ភ្នំគូលែនជាប្រភពផ្តល់ទឹកដល់បណ្តាញផ្លូវទឹកទាំង៣៦នៅខេត្តសៀមរាបទាំងមូល។

ប្រព័ន្ធអេកូឡូស៊ីព្រៃឈើនៅភ្នំគូលែន បានផ្តល់គុណតម្លៃយ៉ាងពិសេសដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានតាមរយៈការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងការទាញយកធនធានធម្មជាតិសម្រាប់ការប្រប្រាស់ផ្ទាល់ក្នុងគ្រួសារ និងពាណិជ្ជកម្ម ជាពិសេសអនុផលព្រៃឈើ ដែលរួមមាន៖ រុក្ខជាតិឱសថ ផ្លែឈើព្រៃ ជ័រទឹក និងគ្រើងលម្អរ។

នៅក្នុងឯកសារនេះ យើងសូមលើកយកនូវរុក្ខជាតិដែលជាអនុផលព្រៃឈើមានតម្លៃសេដ្ឋកិច្ច នៅភ្នំគូលែនចំនួន ២៥ប្រភេទ ដើម្បីជាមូលដ្ឋានចំណេះដឹងដល់ប្រជាសហគមន៍ដែលរស់នៅក្នុងតំបន់ឧទ្យានជាតិភ្នំគូលែន ក៏ដូចជាអ្នកដែលរស់នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិផ្សេងទៀតឱ្យបានដឹងពីប្រភេទអនុផលព្រៃឈើដែលមានតម្លៃសេដ្ឋកិច្ច ដែលអាចជួយឱ្យជីវភាពរបស់ពួកគាត់បានកាន់តែប្រសើរឡើង ជាពិសេសជម្រុញការចូលរួមអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍន៍ដោយចីរភាពនៅកម្ពុជា។

เ◌ี







- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ឫស្សីឈ្លៃ
- ឈ្មោះជាភាសាអង់គ្លេស ៖ Spiny bamboo, giant thorny bamboo, indian thorny bamboo
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Bambusa bambos* (L.) Voss
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់អាស៊ីអាគ្នេយ៍ ចិនភាគខាងត្បូង និងឥណ្ឌា
- របាយប្រភេទ ៖ ជាឫស្សីធំម្យ៉ាង មានរបាយធម្មជាតិដុះនៅក្នុងប្រទេស ចិន ឥណ្ឌា ភូមា ថៃ ឡាវ កម្ពុជា និងនៅវៀតណាម។ បច្ចុប្បន្ន ឫស្សីឈ្លៃ ត្រូវបានគេដាំដុះសឹងពាសពេញតំបន់ត្រូពិក និងតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសនៅប្រទេសឥណ្ឌូនេស៊ី ប្រទេសសិង្ហបុរី ឧបទ្វីបម៉ាឡេស៊ី ថៃ និងប្រទេសហ្វីលីពីន។
- ស្ថានភាពអភិរក្ស ៖ ឫស្សីឈ្លៃមិនទាន់ត្រូវបានគេសិក្សាវាយតម្លៃពីស្ថានភាពគម្រាមកំហែងរបស់វានៅក្នុងបញ្ជីក្រហមរបស់ IUCN នៅឡើយទេ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ស្លឹកខ្ចីរបស់ឫស្សីឈ្លៃពពួកសត្វព្រៃ និងសត្វពាហនៈចូលចិត្តស៊ីណាស់។ ទំពាំងរបស់វាត្រូវបានប្រើប្រាស់ធ្វើជាបន្លែសម្រាប់ស្លរធ្វើម្ហូប។ ដើមរបស់វាត្រូវបានគេប្រើប្រាស់ច្រើនយ៉ាងសម្រាប់សង់ផ្ទះ សាងសង់ស្ពាន និងធ្វើក្បូនជាដើម។ ក្រមួនដែលមានជុំវិញដើមខ្ចីៗរបស់វាគឺគេអាចយកទៅធ្វើក្រដាសកាបោនបាន។







- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ វល្លិ៍ខ្សែឡ
- ឈ្មោះជាភាសាអង់គ្លេស ៖ Willow-leaved climbing fern
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Lygodium salicifolium* C.Presl
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់អាស៊ីអាគ្នេយ៍ ចិន ឥណ្ឌា នេប៉ាល់ ប៊ូតាន
- របាយប្រភេទ ៖ វល្លិ៍ខ្សែឡ មានរបាយដុះសឹងពាសពេញតំបន់អាស៊ីអាគ្នេយ៍ រួមមាន ប្រទេសកម្ពុជា ឡាវ វៀតណាម ថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ភូមា និងមានដុះនៅចិន ឥណ្ឌា នេប៉ាល់ និងប៊ូតាន។ នៅកម្ពុជា វាមានដុះជាច្រើននៅតាមព្រៃស្រោង និងព្រៃពាក់កណ្ដាលស្រោងនៃតំបន់ទំនាបសឹងពាសពេញប្រទេស មាននៅខេត្តសៀមរាប ពោធិ៍សាត់ កោះកុង កំពត ក្រចេះ មណ្ឌលគីរី រតនគីរី ព្រះសីហនុ និងខេត្តព្រះវិហារជាដើម។
- ស្ថានភាពអភិរក្ស ៖ វល្លិ៍ខ្សែឡមិនទាន់ត្រូវបានគេសិក្សាវាយតម្លៃពីស្ថានភាពគម្រាមកំហែងរបស់វានៅក្នុងបញ្ជីក្រហមរបស់ IUCN នៅឡើយទេ ប៉ុន្តែវាត្រូវបានគេចាត់ទុកជាប្រភេទរាតត្បាត ដែលអាចផ្តល់ផលប៉ះពាល់ ដល់ការលូតលាស់របស់ដើមឈើជទៃដែលវាតោងឡើង។
- អត្ថប្រយោជន៍ និងការប្រើប្រាស់៖ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ផ្នែកដើមរបស់វាត្រូវបានគេប្រើប្រាស់ធ្វើជាសម្ភារតម្បាញ ដែលពេលខ្លះត្រូវបានត្បាញលាយជាមួយផ្តៅនិងឫស្សីធ្វើជាកាបូបដៃ មួក កញ្ច្រែង និងវត្ថុអនុស្សាវរីយ៍ជាច្រើនប្រភេទទៀត។ ពេលខ្លះផ្នែកសំបកនៃដើមវល្លិ៍របស់វា ក៏ត្រូវបានគេប្រើប្រាស់សម្រាប់តុបតែងសោភណ្ឌភាពបន្ថែមទៅលើវត្ថុ ឬសម្ភារមួយចំនួន ដែលត្រូវបានគេត្បាញរួចហើយមាន កញ្ច្រែង និងប្រភេទវត្ថុអនុស្សាវរីយ៍ផ្សេងៗទៀត។
-





- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ក្រកោ
- ឈ្មោះជាភាសាអង់គ្លេស ៖ Green Cardamom
- ឈ្មោះវិទ្យាសាស្រ្ត ៖ *Amomum ovoideum* Pierre ex Gagnep
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់អាស៊ីអាគ្នេយ៍
- របាយប្រភេទ ៖ ជារុក្ខជាតិមួយប្រភេទ ដុះច្រើននៅក្នុងព្រៃស្រោង តំបន់ទំនាប និងតំបន់ព្រៃជ្រុះស្លឹក តែក៏មានដុះផង ដែរនៅក្នុងព្រៃស្រោងតំបន់ភ្នំ។ ក្រកោ មានរបាយដុះ សឹងពាសពេញតំបន់អាស៊ីអាគ្នេយ៍ ដែលរបាយធម្មជាតិ របស់វាគេឃើញមានដុះនៅប្រទេសភូមា ថៃ កម្ពុជា ឡាវ វៀតណាម ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី។
- ស្ថានភាពអភិរក្ស ៖ ក្រកោ មិនត្រូវបានគេចាត់ចូលជាប្រភេទទទួលរងការ គម្រាមកំហែងទេ ប៉ុន្តែតម្រូវការដ៏ខ្ពស់នៅក្នុងតំបន់ មូលដ្ឋាន (នៅតំបន់អាស៊ីអាគ្នេយ៍) នៅក្នុងក្បួនឱស ថបុរាណ និងអាហារ បានបង្កឱ្យមានការប្រមូល ក្រកោពីព្រៃនៅក្នុងកម្រិតហួសប្រមាណ ជាពិសេស គឺការប្រមូលគ្រាប់ច្រើនលើសលុប ដែលអាចបង្កឱ្យ បាត់បង់នានាភាពសេនេទិចរបស់វា។ លើសពីនេះ ការបាត់បង់ព្រៃ និងការកាប់បំផ្លាញប្រភេទឈើធំៗ បានធ្វើឱ្យបាត់បង់ជម្រក ម្លប់ដែលសំខាន់ចាំបាច់ សម្រាប់ការលូតលាស់របស់វា។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ នៅតំបន់អាស៊ីអាគ្នេយ៍ ក្រកោត្រូវបានចាត់ទុកជា ប្រភេទអនុផលព្រៃឈើ ដែលផ្លែ និងគ្រាប់របស់វា តែងត្រូវបានប្រជាជនក្នុងតំបន់មូលដ្ឋាន ប្រមូលយក មកប្រើប្រាស់ទាំងនៅក្នុងក្បួនឱសថបុរាណ និង បរិភោគជាអាហារ។ នៅក្នុងក្បួនឱសថបុរាណខ្មែរ ក្រកោត្រូវបានប្រើប្រាស់ព្យាបាលបញ្ហាផ្លូវដង្ហើម និង ប្រព័ន្ធរំលាយអាហារ។





- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ខាន់ម៉ា
- ឈ្មោះជាភាសាអង់គ្លេស ៖ គ្មាន
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Ancistrocladus tectorius* (Lour.) Merr.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់អាស៊ីអាគ្នេយ៍ ចិនភាគខាងត្បូង ឥណ្ឌា
- របាយប្រភេទ ៖ ខាន់ម៉ា ជាប្រភេទរុក្ខជាតិវល្លិ៍មានដុះនៅក្នុងប្រភេទព្រៃតំបន់ទំនាប ព្រៃតំបន់ភ្នំ និងព្រៃស្រោង។ របាយរបស់វានៅក្នុងធម្មជាតិ មានដុះនៅក្នុងប្រទេសកម្ពុជា ចិន ឥណ្ឌា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី ភូមា សិង្ហបុរី ថៃ និងវៀតណាម។ នៅប្រទេសកម្ពុជា ខាន់ម៉ាមានដុះដោយខ្លួនឯងនៅក្នុងព្រៃសឹងគ្រប់ខេត្ត។
- ស្ថានភាពអភិរក្ស ៖ ខាន់ម៉ា មិនទាន់ត្រូវបានគេសិក្សាវាយតម្លៃពីស្ថានភាពគំរាមកំហែងរបស់វា នៅក្នុងបញ្ជីក្រហមរបស់ IUCN នៅឡើយទេ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ស្លឹកខាន់ម៉ា (ស្លឹកចាស់ៗ) ត្រូវបានគេប្រមូលក្រង និងដេរធ្វើជញ្ជាំងផ្ទះ និងប្រក់ដំបូលផ្ទះជាដើម។ រុក្ខជាតិទាំងមូល និងឫសរបស់វាត្រូវបានគេប្រើប្រាស់សម្រាប់ព្យាបាលឈឺឆ្អឹងខ្នងស្លឹក ជួយធ្វើឱ្យស្ត្រីក្រោយឆ្លងទន្លេឆាប់មានកំលាំង ប្រើព្យាបាលគ្រុនចាញ់ និងរាគមួលដោយការដាំទឹកផឹក ឬក៏ត្រាំស្រាផឹក។





- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ កុមារពេជ្យ
- ឈ្មោះជាភាសាអង់គ្លេស ៖ គ្មាន
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Stephania rotunba* Lour.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់ឥណ្ឌូចិន
- របាយប្រភេទ ៖ ឈ្មោះវល្លិ៍ម្យ៉ាងមានប្រវែងពី ៥-១៥ ម ដុះដោយខ្លួនឯងនៅតាមព្រៃភ្នំ ដែនដីសម្បូរថ្ម ឬដំបូកមានជាតិកំបោរ មានរបាយដុះនៅក្នុងប្រទេសកម្ពុជា ឡាវ និង វៀតណាម ជាពិសេសមានច្រើនជាងគេនៅប្រទេស វៀតណាមភាគខាងជើង។ នៅកម្ពុជា កុមារពេជ្យត្រូវបានជួបប្រទះច្រើនជាងគេនៅក្នុងខេត្តព្រះវិហារ។
- ស្ថានភាពអភិរក្ស ៖ កុមារពេជ្យ មិនទាន់ត្រូវបានគេសិក្សាវាយតម្លៃពីស្ថានភាពគំរាមកំហែងរបស់វានៅក្នុងបញ្ជីក្រហមរបស់ IUCN នៅឡើយទេ
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ មើមរបស់កុមារពេជ្យមានទំហំធំៗ រាងមូលពណ៌ត្នោត អាចមានទម្ងន់ដល់២០គីឡូក្រាម។ តាមក្បួនឱសថបុរាណមើមនេះ ជាថ្នាំជំនួយលើកកំលាំង និង សម្រាប់ ព្យាបាលជម្ងឺកន្ទ្រាក់ញាក់សាច់ដុំ ជាពិសេស សាច់ដុំនៃគ្រឿងប្រព័ន្ធរំលាយអាហារ ព្យាបាលការឈឺពោះ ឈឺក្រពះ ឈឺក្បាល ឈឺសន្លាក់ដៃជើង ព្យាបាលស្លេស្ម និងជំនួយផ្លូវភេទ។ ចំណែកវល្លិ៍ និង ស្លឹកព្យាបាល របេងសួត ហឺត រាគមូល ណែនដើមទ្រូង ទឹកនោមផ្អែម និងទម្លាក់រដូវ។ ស្លឹករបស់វាល្វីងប្រើបិតរបួស និងដំបៅពុំរ៉ៃ។ ផ្ការបស់វាជួយដល់ការរំលាយអាហារ និងកន្ទួលសើស្បែក។









- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ គុយ (វល្លិ៍)
- ឈ្មោះជាភាសាអង់គ្លេស ៖ Edible Willughbeia
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Willughbeia edulis* Roxb.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់អាស៊ីអាគ្នេយ៍ បង់ក្លាដែស ឥណ្ឌា
- របាយប្រភេទ ៖ វល្លិ៍ធំមួយប្រភេទវារតោងឡើង មានដុះនៅតំបន់ព្រៃភ្នំ ព្រៃស្រោង និងមានតិចតួចនៅតាមព្រៃរបោះ។ របាយធម្មជាតិរបស់វាមានដុះនៅក្នុងប្រទេសបង់ក្លាដែស ឥណ្ឌា ភូមា ថៃ ម៉ាឡេស៊ី កម្ពុជា ឡាវ និងប្រទេសវៀតណាម។
- ស្ថានភាពអភិរក្ស ៖ គុយជាប្រភេទរុក្ខជាតិដែលមិនទាន់ត្រូវបានគេសិក្សាវាយតម្លៃអំពីស្ថានភាពអភិរក្សរបស់វានៅក្នុងបញ្ជីក្រហម IUCN ទេ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ផ្លែគុយត្រូវបានគេចូលចិត្តបរិភោគណាស់ ហើយពេលខ្លះត្រូវបានគេដាក់លក់នៅតាមទីផ្សារ។ តាមក្បួនឱសថបុរាណ គេកាត់ដើម (វល្លិ៍) វាជាកង់ៗស្ងោរឱ្យនារីទើបសម្រាលកូនហើយផឹកជាថ្នាំជំនួយលើកកំលាំង។ ឫស និងវល្លិ៍ដើមរបស់វាក៏ត្រូវបានគេប្រើប្រាស់ព្យាបាលរាគមូល ជម្ងឺថ្លើម កន្ទាលត្រអាក ដោយដាំទឹក ឬត្រាំស្រាផឹក។ ជ័ររបស់វាគេអាចប្រើសម្រាប់ព្យាបាលដំបៅ ព្យាបាលដង្កូវស៊ីធ្មេញ ដោយបន្តក់ជ័រចូលធ្មេញដង្កូវស៊ី និងព្យាបាលបូស ដោយលាបពីលើបូស។





- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ វល្លិ៍ឆ្លក
- ឈ្មោះជាភាសាអង់គ្លេស ៖ គ្មាន
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Secamone lagenifera* (Kerr) Klack.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍
- របាយប្រភេទ ៖ វល្លិ៍ឆ្លក មានរបាយធម្មជាតិដុះតែនៅក្នុងប្រទេសកម្ពុជា និងប្រទេសថៃប៉ុណ្ណោះ។ នៅប្រទេសកម្ពុជា វល្លិ៍ឆ្លកត្រូវបានគេកត់ត្រាមានដុះនៅក្នុងខេត្តកំពង់ធំ កំពង់ឆ្នាំង និងខេត្តសៀមរាបជាដើម។
- ស្ថានភាពអភិរក្ស ៖ គេមិនទាន់ដឹងអំពីស្ថានភាពអភិរក្សរបស់វល្លិ៍ឆ្លកនៅឡើយទេ (មិនទាន់មានការសិក្សាវាយតម្លៃនៅក្នុងបញ្ជីក្រហម IUCN) ប៉ុន្តែវាក៏មិនត្រូវបានគេពិចារណាចាត់ទុកជាប្រភេទទទួលរងការគម្រាមកំហែងនោះទេ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ មិនមានឯកសារណាមួយបញ្ជាក់ពីការប្រើប្រាស់របស់វល្លិ៍ឆ្លកនោះទេ។ នៅប្រទេសកម្ពុជា វល្លិ៍ឆ្លកត្រូវបានសហគមន៍មូលដ្ឋាននៅលើភ្នំគូលែនយកមកប្រើប្រាស់ធ្វើជាសម្ភារៈតម្បាញ (ដូចវល្លិ៍ឡៃឡដែរ) ដូចជា ធ្វើជាកងដៃ និងវត្ថុអនុស្សាវរីយ៍មួយចំនួនទៀត។



- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ រំចេកស្រុក
- ឈ្មោះជាភាសាអង់គ្លេស ៖ គ្មាន
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Pandanus humilis* Lour.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់អាស៊ីអាគ្នេយ៍
- របាយប្រភេទ ៖ រំចេកស្រុក មានដុះនៅក្នុងព្រៃតំបន់ទំនាបមានសំណើម (ក្បែរមាត់ទឹកដូចជា ស្ទឹង ឬអូរជាដើម) ព្រៃគម្ពោតលើទួល និងមានដុះនៅប្រភេទដីមានថ្មស្ថិតនៅក្បែរមាត់ទឹក។ របាយធម្មជាតិរបស់វាមានដុះនៅកម្ពុជា ឡាវ វៀតណាម ថៃ និងម៉ាឡេស៊ី។
- ស្ថានភាពអភិរក្ស ៖ រំចេកស្រុក មិនត្រូវបានគេព្រួយបារម្ភលើបញ្ហាគម្រាមកំហែងចំពោះវាឡើយ ហើយក៏មិនមានការសិក្សាវាយតម្លៃពីស្ថានភាពអភិរក្សរបស់វានៅក្នុងបញ្ជីក្រហមរបស់IUCN ទេ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ស្លឹករំចេកគេប្រើសម្រាប់ត្បាញកន្ទេល ផ្ការបស់វាក្រអូបគេប្រើសម្រាប់អប់សំពត់អាវ។ ឫសរបស់វាគេប្រើសម្រាប់ធ្វើថ្នាំព្យាបាលជម្ងឺស្វាយ និងប្រមេះ។ ឫសចេញពីដើមមិនទាន់ដល់ដី គេប្រើជំនួយកំលាំងភេទ និងបញ្ចុះទឹកនោម។ ឫសវាប្រើលាយជាមួយគល់ម្នាស់ដាំផឹក ដើម្បីបញ្ចុះទឹកនោម ព្យាបាលនោមតឹង នោមទាស់ នោមចេញឈាម។ គេនិយមដាំរំចេកស្រុកធ្វើជារបងស្រស់។







- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ផ្តៅក្រែក, ផ្តៅគោក, ផ្តៅល្វីង, ផ្តៅកន្ទេល
- ឈ្មោះជាភាសាអង់គ្លេស ៖ Rattan
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Calamus viminalis* Willd.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ អាស៊ីអាគ្នេយ៍ ចិន ឥណ្ឌា បង់ក្លាដែស
- របាយប្រភេទ ៖ ប្រវែងដើម ២-១៥ ម មានដុះនៅក្នុងព្រៃក្រាស់មធ្យម ក្នុងព្រៃស្នាច់ ព្រៃស្រោងតំបន់ទំនាប ព្រៃពាក់កណ្តាលស្រោង ព្រៃជ្រុះស្លឹកចម្រុះ នៅលើដីទួលក្នុងព្រៃជ្រុះស្លឹក Dipterocarp និងធន់នឹងតំបន់គេកាប់ឆ្ការ។ របាយធម្មជាតិរបស់វាមាននៅក្នុងប្រទេសកម្ពុជា ឡាវ វៀតណាម បង់ក្លាដែស ចិន ឥណ្ឌា ភូមា ថៃ ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី។ ប្រភេទផ្តៅក្រែកមានរបាយដុះសឹងពាសពេញប្រទេសកម្ពុជា។
- ស្ថានភាពអភិរក្ស ៖ ផ្តៅក្រែក ជាប្រភេទផ្តៅដែលមិនត្រូវបានគេព្រួយបារម្ភលើបញ្ហាអភិរក្សរបស់វានោះទេ ដោយសារវាជាប្រភេទដែលសម្របខ្លួនទៅនឹងការបាត់បង់ព្រៃឈើ និងធន់បានល្អទៅនឹងការកាប់ប្រមូលយកវាពីព្រៃ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ គមរបស់ផ្តៅក្រែកអាចបរិភោគធ្វើជាបន្លែ ហើយដើម (វល្លិ៍) របស់វាមានគុណភាពល្អ គេយកផ្តៅនេះធ្វើជាទូសៀវភៅ កៅអី សាឡុង កញ្ជើ ល្អី កញ្ច្រែង ឬអាចវេញជាខ្សែ និងធ្វើជាឈើច្រត់ជាដើម។





- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ផ្តៅឈ្វាំង, ផ្តៅជូរ, ក្បង់,កន្ទ្រោង, តាអួញ
- ឈ្មោះជាភាសាអង់គ្លេស ៖ Rattan
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Calamus palustris* Griff.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់អាស៊ីអាគ្នេយ៍
- របាយប្រភេទ ៖ ទំហំដើមធំ ប្រវែងដើមរហូតដល់៣០ម ដុះនៅព្រៃស្រោងតំបន់ទំនាបឬតំបន់ភ្នំមធ្យម ព្រៃពាក់កណ្តាលស្រោង ពេលខ្លះមានដុះតាមព្រៃលិចទឹកជាដើម និងជួនកាលដុះនៅក្បែរភូមិ។ របាយរបស់វាមានដុះនៅកម្ពុជា ឡាវ វៀតណាម ភូមា ថៃ និងម៉ាឡេស៊ី។ ផ្តៅឈ្វាំងត្រូវបានគេប្រទះឃើញមានដុះនៅក្នុងព្រៃក្រាស់ល្មមសឹងពាសពេញប្រទេសកម្ពុជា។
- ស្ថានភាពអភិរក្ស ៖ ផ្តៅឈ្វាំង ជាប្រភេទផ្តៅដែលមិនត្រូវបានគេព្រួយបារម្ភលើបញ្ហាអភិរក្សរបស់វានៅឡើយទេ ហើយក៏មិនទាន់មានការសិក្សាវាយតម្លៃស្ថានភាពអភិរក្សរបស់វានៅក្នុងបញ្ជីក្រហម IUCN ដែរ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ផ្លែ និងគមរបស់ផ្តៅឈ្វាំងអាចបរិភោគបាន ដើមរបស់វាទន់ និងជាប់ល្អណាស់ គេប្រើការបានច្រើនយ៉ាងសម្រាប់ធ្វើទូរសៀវភៅ កៅអី ត្បាញកន្ត្រក កញ្ច្រែងល្អី និងវេញជាខ្សែជាដើម។







- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ផ្ដៅសោម
- ឈ្មោះជាភាសាអង់គ្លេស ៖ Rattan
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Daemonorops jenkinsiana* (Griff.) Mart.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់អាស៊ីអាគ្នេយ៍ ចិន ឥណ្ឌា នេប៉ាល់ ប៊ុយតាន
- របាយប្រភេទ ៖ ប្រវែងដើមរហូតដល់ ៣០ម ដុះនៅក្នុងព្រៃស្រោង តំបន់ទំនាបឬតំបន់ភ្នំមធ្យម តំបន់មានសំណើមនៃព្រៃពាក់កណ្ដាលស្រោង ព្រៃលិចទឹក ហើយវាធន់នឹងតំបន់គេរុករាន។ របាយធម្មជាតិរបស់វាមានដុះនៅកម្ពុជា ឡាវ វៀតណាម បង់ក្លាដែស ប៊ុយតាន ចិន ឥណ្ឌា ភូមា នេប៉ាល់ និងប្រទេសថៃ។ ផ្ដៅសោមមានរបាយដុះសឹងពាសពេញប្រទេសកម្ពុជា។
- ស្ថានភាពអភិរក្ស ៖ ផ្ដៅសោម ជាប្រភេទផ្ដៅដែលមិនត្រូវបានគេព្រួយបារម្ភលើបញ្ហាអភិរក្សរបស់វានៅឡើយទេ ហើយក៏មិនទាន់មានការសិក្សាវាយតម្លៃស្ថានភាពអភិរក្សរបស់វានៅក្នុងបញ្ជីក្រហម IUCN ដែរ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ គមរបស់ផ្ដៅសោមត្រូវបានគេយកមកបរិភោគធ្វើជាបន្លែ។ ផ្នែកដើមរបស់វាងាយពត់បាន ដែលត្រូវបានគេប្រមូលយកមកប្រើប្រាស់នៅក្នុងផលិតកម្មគ្រឿងសង្ហារឹម (ធ្វើតុ ទូ កៅអី...)។







- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ផ្ដៅដំបង
- ឈ្មោះជាភាសាអង់គ្លេស ៖ Rattan
- ឈ្មោះវិទ្យាសាស្រ្ត ៖ *Calamus rudentum* Lour.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់អាស៊ីអាគ្នេយ៍
- របាយប្រភេទ ៖ មានទំហំដើមធំ ប្រវែងដើមវែងរហូតដល់ ១០០មជុះ នៅក្នុងព្រៃស្រោងតំបន់ទំនាប និងព្រៃលូតលាស់បន្ទាប់ (Succession Forest) ព្រៃពាក់កណ្ដាលស្រោង និងព្រៃលិចទឹកដែលហ៊ុំព័ទ្ធដោយព្រៃជ្រុះស្លឹក Dipterocarp។ របាយក្នុងធម្មជាតិរបស់វាមានដុះនៅកម្ពុជា ឡាវភាគខាងត្បូង វៀតណាម ភូមា និងប្រទេសថៃ។ ផ្ដៅដំបង មានរបាយពាសពេញភាគខាងកើត ភាគអាគ្នេយ៍ និងភាគនិរតីនៃប្រទេសកម្ពុជា។
- ស្ថានភាពអភិរក្ស ៖ ការអភិរក្សផ្ដៅដំបងមិនទាន់ត្រូវបានគេយកចិត្តទុក និងដឹងពីស្ថានភាពអភិរក្សបច្ចុប្បន្នរបស់វានៅឡើយទេ ហើយក៏មិនទាន់មានការសិក្សាវាយតម្លៃស្ថានភាពអភិរក្សរបស់វានៅក្នុងបញ្ជីក្រហម IUCN ដែរ។ តែយ៉ាងណាវិញ ផ្ដៅដំបងត្រូវបានរាយការណ៍ថាជាប្រភេទផ្ដៅដែលគេចូលចិត្តប្រមូលសម្រាប់ធ្វើការជួញដូរនៅវៀតណាម ដែលបង្កធ្វើឱ្យមានការគម្រាមកំហែងនៃការប្រមូលហួសកម្រិតពីព្រៃ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ផ្លែរបស់ផ្ដៅដំបងអាចបរិភោគបាន ដើមរបស់វាគេប្រើការបានច្រើនយ៉ាងដូចជា ធ្វើក្បូន ធ្វើខ្សែ ធ្វើពួរចងនាវា ធ្វើទូរសៀវភៅ កៅអី តុ ទូ កន្ត្រកកញ្ច្រែង ល្អី ខ្សែចងសត្វពាហនៈ និងធ្វើឈើច្រត់ប្រណិត ។ល។







- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ សែសឹង, ផ្តៅចង្រិត, ផ្តៅល្អាក់, ផ្តៅសាង, ផ្តៅសែង
- ឈ្មោះជាភាសាអង់គ្លេស ៖ Rattan
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Calamus tetradactylus* Hance
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ នៅស្រុកហៃណាំ (Hainan) ប្រទេសចិន
- របាយប្រភេទ ៖ ប្រភេទផ្តៅដ៏ធំ មានប្រវែង ២០-៧០ម មានដុះនៅក្នុងតំបន់ព្រៃស្រោងតំបន់ទំនាប និងតំបន់ព្រៃជ្រុះស្លឹកចម្រុះទទួលរងការរំខាន។ របាយធម្មជាតិរបស់វាមានដុះនៅក្នុងកម្ពុជា ឡាវ វៀតណាម ថៃ និងចិន។ នៅប្រទេសកម្ពុជា គេប្រទះឃើញវាមានដុះនៅតាមព្រៃនៅជិតមាត់ទឹក និងតាមតំបន់ទំនាបសឹងពាសពេញប្រទេសកម្ពុជា។
- ស្ថានភាពអភិរក្ស ៖ សែសឹងមិនទាន់ត្រូវបានគេដឹងអំពីស្ថានភាពអភិរក្សរបស់វានៅឡើយទេ ហើយក៏មិនទាន់មានការសិក្សាវាយតម្លៃស្ថានភាពអភិរក្សរបស់វានៅក្នុងបញ្ជីក្រហម IUCN ដែរ។ នៅប្រទេសថៃ សែសឹងត្រូវបានចាត់ទុកថាជាប្រភេទផ្តៅមិនទាន់ទទួលរងការគម្រាមកំហែងនៅឡើយទេ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ផ្លែរបស់ផ្តៅសែសឹងនេះអាចបរិភោគបាន ដើមរបស់វាគេអាចប្រើប្រាស់ធ្វើ គុ ទូ កៅអី និងវេញជាខ្សែរពួរជាដើម ហើយឫសរបស់វាគេអាចយកស្ងោរផឹកព្យាបាលអាការៈគ្រុនក្តៅ។





- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ចង្អូរ, ផ្ដៅត្រែសអំបោះ
- ឈ្មោះជាភាសាអង់គ្លេស ៖ Rattan
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Plectocomia pierreana* Becc.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់អាស៊ីអាគ្នេយ៍ និងប្រទេសចិន
- របាយប្រភេទ ៖ មានប្រវែង ១០-៣០ម ដុះនៅក្នុងព្រៃស្រោងតំបន់ទំនាប ឬតំបន់ភ្នំ និងនៅក្នុងព្រៃពាក់កណ្ដាលស្រោងទទួលរងការរំខាន។ របាយធម្មជាតិរបស់វាមាននៅក្នុងកម្ពុជា ឡាវ វៀតណាម ថៃ និងប្រទេសចិន។ ផ្ដៅត្រែសអំបោះមានដុះសឹងពាសពេញតំបន់ព្រៃក្រាស់ និងព្រៃស្រោងនៅប្រទេសកម្ពុជា និងសម្បូរដុះនៅតាមជួរភ្នំក្រវាញ។
- ស្ថានភាពអភិរក្ស ៖ ផ្ដៅត្រែសអំបោះមិនទាន់ត្រូវបានគេដឹងអំពីស្ថានភាពអភិរក្សក្នុងពេលបច្ចុប្បន្នរបស់វានៅឡើយទេ ហើយក៏មិនទាន់មានការសិក្សាវាយតម្លៃស្ថានភាពអភិរក្សរបស់វានៅក្នុងបញ្ជីក្រហម IUCN ដែរ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ផ្នែកដើមរបស់វាគេអាចប្រើប្រាស់សម្រាប់ធ្វើជាខ្សែពួរ និងធ្វើជាកញ្ជើ ល្អី ទូ កៅអី ។ល។





- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ត្រាច, ត្រាច-ស, ត្រាចស្នែង, ត្រាចស្រ
- ឈ្មោះជាភាសាអង់គ្លេស ៖ គ្មាន
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Dipterocarpus intricatus* Dyer
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់ឥណ្ឌូចិន
- របាយប្រភេទ ៖ ជាព្រឹក្សមានកម្ពស់ ១៥-៣០ម ដុះនៅតំបន់ព្រៃជ្រុះស្លឹក តិចតួចជួបប្រទះវានៅតាមព្រៃតំបន់ទំនាបលិចទឹក។ របាយធម្មជាតិរបស់វាមាននៅក្នុងកម្ពុជា ឡាវ វៀតណាម និងថៃ។ នៅកម្ពុជា ត្រាចមានដុះនៅក្នុងកំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ កំពត កណ្ដាល សៀមរាប និងស្ទឹងត្រែង។
- ស្ថានភាពអភិរក្ស ៖ ត្រាច ត្រូវបានវាយតម្លៃចាត់បញ្ចូលជាប្រភេទ "ទទួលរងគ្រោះ(EN)" នៅក្នុងបញ្ជីក្រហមIUCN។វាទទួលរងការគម្រាមកំហែងដោយសារការបាត់បង់ និងការថយចុះទីជម្រក ដែលបណ្ដាលមកពីការរាតដីធ្វើកសិកម្ម ជាពិសេសការពង្រីកដីធ្វើស្រែ ចម្ការចន្ទី និងដំឡូងជាដើម។ លើសពីនេះ ការដកហូតឈើត្រាចហួសកម្រិតពីព្រៃក៏ជាកត្តាគម្រាមកំហែងដល់វាផងដែរ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ដើមត្រាចមានពណ៌ក្រហមក្រម៉ៅ ជាប្រភេទឈើមានតម្លៃគួរសម ដែលគេប្រើប្រាស់សម្រាប់សង់ផ្ទះ ធ្វើគ្រឿងសង្ហារឹម ឬធ្វើរទេះគោជាដើម។ ជ័រត្រាចគេច្រើនប្រើសម្រាប់ធ្វើចន្លុះ។ ឬសត្រាចត្រូវបានគេប្រើព្យាបាលគ្រេចចង្កេះ ដើមរបស់វាប្រើជំនួយកំលាំង បំបាត់ចុកចាប់ រាគមួល ហើយខ្លឹមរបស់វាប្រើព្យាបាលផ្សះថ្លើម ដោយប្រើដាំទឹកផឹក។





- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ក្រពុលបាយ
- ឈ្មោះជាភាសាអង់គ្លេស ៖ Indian laurel, Soft bollygum, Bolly beech, Brown bollygum,
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Litsea glutinosa* (Lour.) C.B.Rob.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ នៅតំបន់អាស៊ីត្រូពិក
- របាយប្រភេទ ៖ ព្រឹក្សមានកម្ពស់ ៥-១៥ម ដុះក្នុងព្រៃធំ និងព្រៃក្រាស់មធ្យមនៅតំបន់អាស៊ីត្រូពិក។ របាយធម្មជាតិរបស់វាមាននៅឥណ្ឌា បង់ក្លាដែស ម៉ាឡេស៊ី កម្ពុជា ឡាវ ភូមា នេប៉ាល់ ញូហ្គីនៀ ឥណ្ឌូនេស៊ី ហ្វីលីពីន ស្រីលង្កា ថៃ និងវៀតណាម។ នៅកម្ពុជា វាមានដុះនៅខេត្តកំពង់ឆ្នាំង កំពត កោះកុង សៀមរាប និងនៅតំបន់ទន្លេមេគង្គ (រវាងក្រចេះ និងស្ទឹងត្រែង)។
- ស្ថានភាពអភិរក្ស ៖ ក្រពុលបាយ មិនទាន់ត្រូវបានគេដឹងអំពីស្ថានភាពអភិរក្សក្នុងពេលបច្ចុប្បន្នរបស់វានៅឡើយទេ ហើយក៏មិនទាន់មានការសិក្សាវាយតម្លៃស្ថានភាពអភិរក្សរបស់វានៅក្នុងបញ្ជីក្រហម IUCN ដែរ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ស្លឹកក្រពុលបាយអាចធ្វើចំណីសត្វគោ-ក្របីបាន។ ក្នុងក្បួនឱសថបុរាណខ្មែរ សំបកដើមវាបុកលម្អិតប្រើសម្រាប់ព្យាបាលបូសរយ រលាកដោះ រើម (ប្រើខាងក្រៅ) ហើយសំបកវាក៏អាចដាំទឹកផឹកព្យាបាលរមាស់ ឈឺចាប់ក្នុងស្បូន ចុកសាច់ដុំ ស្ពឹក-ខ្វិន និងឈឺក្នុងឆ្អឹង។ ស្លឹកប្រើដូចសំបកដែរ បុកបិទលើរបួសជួយឃាត់ឈាម។ ឫសព្យាបាលរាគមួល និងរលាកពោះវៀន (ដាំផឹក)។







- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ រំដួល ( ស៊ីផ្លែ )
- ឈ្មោះជាភាសាអង់គ្លេស ៖ White Cheesewood
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Melodorum fruticosum* Lour.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់អាស៊ីអាគ្នេយ៍
- របាយប្រភេទ ៖ ជាព្រឹក្សមានកម្ពស់ ៣ - ១០ម មានរបាយធម្មជាតិនៅក្នុងកម្ពុជា ឡាវ វៀតណាម និងប្រទេសថៃ។ នៅកម្ពុជា រំដួលមានដុះនៅខេត្តកំពង់ធំ សៀមរាប និងតំបន់ទន្លេមេគង្គ (រវាងខេត្តក្រចេះ និងស្ទឹងត្រែង )។
- ស្ថានភាពអភិរក្ស ៖ រំដួល មិនទាន់ត្រូវបានគេដឹងអំពីស្ថានភាពអភិរក្សក្នុងពេលបច្ចុប្បន្នរបស់វានៅឡើយទេ ហើយក៏មិនទាន់មានការសិក្សាវាយតម្លៃស្ថានភាពអភិរក្សរបស់វានៅក្នុងបញ្ជីក្រហម IUCN ដែរ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ផ្លែរំដួល គេចូលចិត្តបរិភោគណាស់ និងជួនកាលមានដាក់លក់នៅតាមទីផ្សារផងដែរ។ ផ្ការបស់វាមានក្លិន ហើយពេលខ្លះគេដាំដើមរំដួលនៅក្នុងសួនឧទ្យាន ដើម្បីតុបតែងភាពស្រស់ស្អាត និងមានភាពទាក់ទាញ។





- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ កប្ងូរ
- ឈ្មោះជាភាសាអង់គ្លេស ៖ Camphor Tree, Camphorwood, Camphor Laurel
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Cinnamomum camphora* (L.) J. Presl
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់អាស៊ីប៉ែកខាងកើត(ចិន ជប៉ុន កូរ៉េ វៀតណាម)
- របាយប្រភេទ ៖ ជាព្រឹក្សមានកម្ពស់ ១០ - ១៥ម ដុះនៅតំបន់ព្រៃបឋម (Primary Forest) ព្រៃក្បែរមាត់ទឹក នៅតាមជាយតំបន់ព្រៃរងទឹកភ្លៀង ឬនៅតំបន់ក្បែរផ្លូវ ដែលរបាយធម្មជាតិរបស់វាមានដុះនៅវៀតណាម ចិន ជប៉ុន និងកូរ៉េ ហើយត្រូវបានគេនាំចូលមកដាំ (Introduced) នៅប្រទេសជាច្រើនរួមមាន កម្ពុជា ឥណ្ឌា បង់ក្លាដែស ហ្វីជី នេប៉ាល់ និងអាមេរិកជាដើម។
- ស្ថានភាពអតិរាត្យ ៖ កប្ងូរ ជាប្រភេទដែលមិនត្រូវបានគេព្រួយបារម្ភលើបញ្ហាអតិរាត្យរបស់វានោះទេ តែយ៉ាងណាវាត្រូវបានគេគេចាត់បញ្ចូលជាប្រភេទរាតត្បាតនៅក្នុងតំបន់នាំចូលមកដាំ ដោយសារវាមានគម្របដើមក្រាស់ (Dense Canopy) និងមានប្រកួតប្រជែងក្នុងការលូតលាស់ជាមួយប្រភេទរុក្ខជាតិដើមក្នុងតំបន់ (Native Species)។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ដើមរបស់កប្ងូរអាចប្រើប្រាស់ធ្វើជាឈើសម្រាប់សាងសង់ ហើយគេអាចចំរាញ់វាយកប្រេងដែលមានក្លិនប្រហើរឆ្ងួល សម្រាប់ប្រើប្រាស់ជាថ្នាំឈឺក្បាល វិលមុខ និងតឹងច្រមុះ។ ប្រេងរបស់វាត្រូវបានគេចំរាញ់ចេញពីផ្នែកឫស មែកនៃដើមឈើ ឬស្លឹកបៃតង។







- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ស្ដៅ
- ឈ្មោះជាភាសាអង់គ្លេស ៖ Neem Tree, Margosa Tree
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Azadirachta indica* Ant. Juss.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់ឧបទ្វីបឥណ្ឌា និងនៅតំបន់អាស៊ីអាគ្នេយ៍
- របាយប្រភេទ ៖ ដើមឈើកម្ពស់ ១០-១៥ម ដុះសឹងគ្រប់ទីកន្លែងនៅតំបន់ទំនាបត្រូពិក នៅតាមតំបន់ទីវាល និងមានដុះនៅតំបន់ខ្ពង់រាប។ របាយធម្មជាតិរបស់ស្ដៅហាក់មិនមានភាពច្បាស់លាស់នៅឡើយទេ ប៉ុន្តែវាត្រូវបានគេជឿថាមានប្រភពនៅឥណ្ឌា ប៉ាគីស្ថាន បង់ក្លាដែស ស្រីលង្ការ និងនៅភូមា ឥណ្ឌូនេស៊ី និងម៉ាឡេស៊ី។ វាត្រូវបានគេនាំចូលមកដាំនៅប្រទេសជាច្រើនក្នុងពិភពលោក។
- ស្ថានភាពអភិរក្ស ៖ ស្ដៅ ត្រូវបានវាយតម្លៃចាត់បញ្ចូលទៅក្នុងក្រុម "មានការព្រួយបារម្ភតិចតួច (Least Concern)" នៅក្នុងបញ្ជីក្រហម IUCN។ ស្ដៅ ត្រូវបានគេចូលចិត្តដាំយ៉ាងទូលំទូលាយ ប៉ុន្តែព័ត៌មានអំពីប៉ូប៉ុយឡាស្យុងរបស់វាក្នុងតំបន់ព្រៃធម្មជាតិត្រូវបានគេដឹងតិចតួចណាស់។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ស្លឹក និងផ្កាស្ដៅត្រូវបានគេចូលចិត្តបរិភោគជាបន្លែដោយគ្រាន់តែជ្រលក់ទឹកក្ដៅជាមុន ដើម្បីកុំឱ្យវាល្វីងពេក។ ទឹកស្ងោរសំបកដើមអាចព្យាបាលគ្រុនចាញ់ ស្បែកលឿង គ្រុន ថ្លើម និងលាងរបួស។ សំបកឫស និងផ្លែខ្ចីជាថ្នាំប៉ូវ និងបញ្ចុះកំដៅ។ ស្លឹកបុកពពោកសម្រកហើម កើតពិស បូស យកស្លឹកដាំទឹកលាងឱ្យសះ។ ផ្កាក្រៀម ប្រើប៉ូវ លាងឈាម ហើយផ្លែវាជាថ្នាំបញ្ចុះនិងទំលាក់ព្រូន និងជួយបញ្ហាសើស្បែក។ សំបកដើម ជ័រ ស្លឹក គ្រាប់ ព្យាបាលពស់ចឹក និងខ្យាដំរីទិច។ ខ្លឹម ជាថ្នាំស្ត្រីធ្លាក់ស និងចំរើនអាយុ។



- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ផ្ចឹក
- ឈ្មោះជាភាសាអង់គ្លេស ៖ គ្មាន
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Shorea obtusa* Wall. ex Blume
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់ឧបទ្វីបឥណ្ឌូចិន
- របាយប្រភេទ ៖ ផ្ចឹកជាព្រឹក្ស កម្ពស់ ១០-៣០ម ដុះក្នុងព្រៃស្រោងលើទួល ឬភ្នំ (មានរយៈកម្ពស់ពី ១៥០-១៣០០) មានរបាយធម្មជាតិដុះនៅក្នុងឧបទ្វីបឥណ្ឌូចិន (រួមមានកម្ពុជា ឡាវ វៀតណាម ថៃ និងភូមា)។ នៅប្រទេសកម្ពុជា ផ្ចឹកមានដុះនៅខេត្តកំពង់ កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ កំពត ព្រៃវែង ពោធិ៍សាត់ និងស្ទឹងត្រែង។
- ស្ថានភាពអភិរក្ស ៖ ផ្ចឹកត្រូវបានវាយតម្លៃចាត់បញ្ចូលទៅក្នុងក្រុម "ជិតទទួលរងការគម្រាមកំហែង (Near Threatened)" នៅក្នុងបញ្ជីក្រហម IUCN។ ចំនួនប៉ូប៊ុយឡាស្យុងរបស់ផ្ចឹកមានការថយចុះដោយសារការបាត់បង់ទីជម្រក និងការកែប្រែដីព្រៃទៅជាដីកសិកម្ម។ ផ្ចឹកក៏ត្រូវបានទទួលរងការគម្រាមកំហែងដោយសារការកាប់យកឈើសម្រាប់ការជួញដូរផងដែរ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ជាប្រភេទឈើលេខមួយ រឹងល្អ សម្រាប់ធ្វើជាស្ពាន ធ្វើកំណាល់ ឬសម្រាប់សាងសង់ផ្ទះ។ បើដាក់ហាលភ្លៀងឈើនេះជាប់ត្រឹមតែ ១០ - ១៥ ឆ្នាំទេ តែបើនៅក្នុងម្លប់អាចជាប់យូរពី ៥០ - ៦០ ឆ្នាំ។ ជ័ររបស់វាគេអាចប្រើធ្វើជាចន្លុះ ឬផ្សំធ្វើឱសថគ្រុនចាញ់។ ជ័ររបស់វាគេប្រើឱ្យជ្រូកស៊ីកុំឱ្យមានកូន និងសំបកប្រើដាំទឹកផឹកសម្រាប់ស្ត្រីក្រោយឆ្លងទន្លេ ដើម្បីជំនួយសុខភាព។ ខ្លឹម ប្រើសម្រាប់ផ្សះ ធ្លាក់ស ចំរើនអាយុ ហើយឫសរបស់វា ប្រើជាថ្នាំពន្យាកំណើត (ដោយដាំទឹកផឹក)។





- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ឈើទាលទឹក, ឈើទាលបាយ, ឈើទាលធំ
- ឈ្មោះជាភាសាអង់គ្លេស ៖ គ្មាន
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Dipterocarpus alatus* Roxb. ex G. Don
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ ឧបទ្វីបឥណ្ឌូចិន និងថ្នា
- របាយប្រភេទ ៖ ជាព្រឹក្ស កម្ពស់ ២៥ - ៤០ម ដុះនៅក្នុងព្រៃស្រោង ឬព្រៃក្រាស់មធ្យម នៅរយៈកម្ពស់ពី៣០០ - ៩០០ម ដែលមានរបាយធម្មជាតិដុះនៅក្នុងឧបទ្វីបឥណ្ឌូចិន (កម្ពុជា ឡាវ វៀតណាម ថៃ ភូមា) និងថ្នា(Malay Peninsula) ឥណ្ឌា ស្រីលង្កា និងបង់ក្លាដែស។ នៅកម្ពុជា ឈើទាលទឹកមានដុះនៅក្នុងខេត្តកំពង់ស្ពឺ កំពង់ធំ សៀមរាប កំពត ពោធិ៍សាត់ និងស្ទឹងត្រែង។
- ស្ថានភាពអភិរក្ស ៖ ឈើទាលទឹកត្រូវបានវាយតម្លៃចាត់បញ្ចូលទៅក្នុងក្រុម "ងាយរងគ្រោះ (Vulnerable)" នៅក្នុងបញ្ជីក្រហម IUCN។ ចំនួនប៉ូប៉ុយឡាស្យុងរបស់វាមានការថយចុះដោយសារការកាប់បំផ្លាញព្រៃឈើ ការកាប់ដកហូតឈើ និងការដកហូតយកជ័ររបស់វាហួសកម្រិតសម្រាប់ធ្វើពាណិជ្ជកម្ម។ ឈើទាលទឹកកំពុងត្រូវបានគេព្រួយបារម្ភពីការបាត់បង់នានាភាពនៃសេនេទិចរបស់ប៉ូប៉ុយឡាស្យុងប្រភេទរបស់វា។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ឈើមានតម្លៃណាស់សម្រាប់សាងសង់ផ្ទះ ឬធ្វើប្រដាប់តាំងលម្អ។ ជារឿយៗ គេតែងចំរាញ់យកជ័រពីដើម សម្រាប់ប្រើការផ្សេងៗដូចជា បិទទូក ឬទុកធ្វើថ្នាំរម្ងាប់រោគ។ គ្រូថ្នាំខ្មែរយកជ័រឈើទាលទឹកលាយជាមួយក្រមួនធ្វើថ្នាំបំពោកលើដំបៅរលួយ។ សំបកដើមតូចៗទើបទងមានស្លឹក ២-៤ គេប្រើជាថ្នាំព្យាបាលជម្ងឺ សន្លាក់ឆ្អឹង ថ្លើម ។ល។ ពេទ្យសត្វស្ងោរសំបកឱ្យសត្វពាហនៈផឹក ដើម្បីឱ្យវាស៊ីស្មៅបានច្រើនឆាប់ធំធាត់។





- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ គូលែន
- ឈ្មោះជាភាសាអង់គ្លេស ៖ Lychee, Litchi
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Litchi chinensis* Sonn.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ ចិនភាគខាងត្បូង និងវៀតណាមភាគខាងជើង
- របាយប្រភេទ ៖ ជាព្រឹក្ស កម្ពស់ ៨-១០ម ដុះនៅប្រទេសចិនខាងត្បូង និងវៀតណាមខាងជើង ហើយពួកជ្វា (Malaysia) បាននាំមកដាំយូរណាស់ហើយ។ នៅប្រទេសកម្ពុជា គេឃើញដើមគូលែនដុះឯងៗ តែលើភ្នំគូលែនទេ តែក៏ត្រូវបានគេដាំជាចម្ការផងដែរ។
- ស្ថានភាពអភិរក្ស ៖ គូលែនមិនទាន់ត្រូវបានគេដឹងពីស្ថានភាពអភិរក្សរបស់វាទេ ហើយក៏មិនទាន់មានការសិក្សាវាយតម្លៃពីស្ថានភាពគម្រាមកំហែងរបស់វានៅក្នុងបញ្ជីក្រហមរបស់ IUCN ដែរ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ផ្លែសម្រាប់ធ្វើជាអាហារ ផ្លែស្រស់មានជីវជាតិ A និង B ជាច្រើន តែផ្លែក្រាមគ្មានជីវជាតិនោះទេ ផ្លែខ្ចីគេប្រើធ្វើថ្នាំអុតធំ។ គ្រូថ្នាំបុរាណស្ងោរផ្កា សំបក និង ឫសគូលែនព្យាបាលជម្ងឺបំពង់ក។ គ្រាប់ជាថ្នាំពោះវៀន និងព្យាបាលជម្ងឺខ្លួនចុក ពងកោប រំលាយពក ឈឺក្រពះ ឈឺពោះវៀនតូច។ សាច់អាចបំបាត់ការស្រេកទឹក ហត់ហើមស្ងួត កូនកណ្ដុរ។







- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ អន្ទង់-ស
- ឈ្មោះជាភាសាអង់គ្លេស ៖ Malaysian Ginseng
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Eurycoma longifolia* Jack
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់អាស៊ីអាគ្នេយ៍
- របាយប្រភេទ ៖ អន្ទង់-ស ជាចុល្លព្រឹក្សម្យ៉ាងកម្ពស់ ២-៥ម មានដុះនៅក្នុងព្រៃបឋម (Primary Forest) ព្រៃដុះបន្តបន្ទាប់ (Succession Forest) ព្រៃជ្រុះស្លឹកចម្រុះរងទឹកភ្លៀង ព្រៃតំបន់ឆ្នេរដីខ្សាច់ និងមានដុះនៅលើដីថ្មភក់ជាដើម ដែលរបាយធម្មជាតិរបស់វាមានដុះនៅកម្ពុជា ឡាវ វៀតណាម ថៃ ភូមា និងម៉ាឡេស៊ី។
- ស្ថានភាពអភិរក្ស ៖ អន្ទង់-ស មិនទាន់ត្រូវបានសិក្សាវាយតម្លៃពីស្ថានភាពគម្រាមកំហែងរបស់វានៅក្នុងបញ្ជីក្រហមរបស់ IUCN ទេ ប៉ុន្តែវាត្រូវបានគេដឹងថាផ្នែកឫសរបស់វាត្រូវបានគេប្រើប្រាស់ច្រើនជាងគេ ដែលការប្រមូលអាចត្រូវបានធ្វើឡើងដោយការគាស់រលើងផ្តួលដើមទាំងមូលដើម្បីប្រមូលយកឫស ដែលជាមូលហេតុធ្វើឱ្យមានការព្រួយបារម្ភលើនិរន្តរភាពនៃការប្រើប្រាស់របស់វា។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ សំបក ផ្លែ និងឫស សម្រាប់ធ្វើឱសថបុរាណ។ សំបកជាថ្នាំសម្រាប់រោគ ឬព្យាបាលបញ្ហាក្នុងប្រព័ន្ធរំលាយអាហារ ផ្លែជាឱសថរាគមូល ឫសសម្រាប់បន្សាបពិស និងធ្វើឱ្យបាត់ស្រវឹងស្រា។







- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ មើមថ្នាំចិន, ប៉ប្រើស
- ឈ្មោះជាភាសាអង់គ្លេស ៖ China Root, Sarsaparilla
- ឈ្មោះវិទ្យាសាស្ត្រ ៖ Wall. ex Roxb.
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់ឥណ្ឌូចិន ប្រទេសចិន និងឥណ្ឌា
- របាយប្រភេទ ៖ មើមថ្នាំចិន ជាប្រភេទវល្លិ៍មានបន្លាវារឡើងឈើធំៗ ក្នុងព្រៃក្រាស់ និងព្រៃស្រោង ដុះលើថ្ម លើភ្នំ ដែលមានកម្ពស់ដល់ ១៥០០ម។ របាយធម្មជាតិរបស់វាមានដុះនៅក្នុងប្រទេសឥណ្ឌា ចិន ថៃ កម្ពុជា ឡាវ វៀតណាម និងភូមា។
- ស្ថានភាពអភិរក្ស ៖ មើមថ្នាំចិន មិនទាន់ត្រូវបានគេដឹងពីស្ថានភាពអភិរក្សរបស់វានៅឡើយទេ ហើយក៏មិនទាន់មានការសិក្សាវាយតម្លៃពីស្ថានភាពគម្រាមកំហែងរបស់វានៅក្នុងបញ្ជីក្រហមរបស់ IUCN ដែរ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ដើមវាអាចប្រើធ្វើចំណងបាន មើមវាគេតែងត្រាំស្រាផឹកជាថ្នាំលើកកំលាំង។







- ឈ្មោះខ្មែរ/ឈ្មោះក្នុងតំបន់ ៖ ចន្ទន៍ក្រស្នា
- ឈ្មោះជាភាសាអង់គ្លេស ៖ Agarwood
- ឈ្មោះវិទ្យាសាស្ត្រ ៖ *Aquilaria crassna* Pierre ex Lecomte
- ប្រភពដើម/ដើមកំណើតប្រភេទ ៖ តំបន់ឥណ្ឌូចិន
- របាយប្រភេទ ៖ ឈើធំកម្ពស់ ១៥-២០ម ដុះក្នុងព្រៃស្រោងដីទំនាប ព្រៃបឋម ព្រៃដុះបន្តបន្ទាប់ នៅលើប្រភេទដីមានថ្ម និងនៅតាមតំបន់ក្បែរមាត់ទឹកក្នុងព្រៃ។ របាយធម្មជាតិរបស់ចន្ទន៍ក្រស្នាមាននៅក្នុងប្រទេសកម្ពុជា ឡាវ វៀតណាម និងថៃ។ នៅកម្ពុជា វាមានដុះនៅខេត្តកំពង់ធំ សៀមរាប កំពត កណ្តាល និងខេត្តកោះកុង។
- ស្ថានភាពអភិរក្ស ៖ ច័ន្ទក្រស្នា ត្រូវវាយតម្លៃចាត់បញ្ចូលទៅក្នុងក្រុម "ទទួលរងគ្រោះធ្ងន់ធ្ងរ (Critically Endangered) នៅក្នុងបញ្ជីក្រហម IUCN។ វាទទួលរងការគម្រាមកំហែងធ្ងន់ធ្ងរដោយសារការដកហូតហួសកម្រិតសម្រាប់ យកខ្លឹមនិងប្រេងក្រអូបរបស់វាធ្វើពាណិជ្ជកម្ម។ នៅកម្ពុជា ច័ន្ទក្រស្នាត្រូវបានគេវាយតម្លៃថានៅមានចំនួន តិចតួច និងនៅមានតែក្នុងតំបន់ការពារធម្មជាតិតែប៉ុណ្ណោះ។
- អត្ថប្រយោជន៍ និងការប្រើប្រាស់ ៖ ខ្លឹមច័ន្ទក្រស្នាក្រអូបណាស់ ប្រើធ្វើបុណ្យខ្មោច ដោយឆ្លាក់ជារូបផ្កាក្នុងខ្លឹម ដែលគេកាត់ស្តើងៗ ហើយដុតពេលបូជាសព។ ខ្លឹមរបស់វា ប្រើជំនួយរំលាយអាហារ ដើរខ្យល់ កាត់ស្លេស្ម បំបាត់ក្លិន ឆ្ងាញ់បាយ បំបាត់ឈឺចុកចាប់ បំបាត់រលាក បំបាត់ឃ្លង់ ធ្វើឱ្យចេញញើស ជំនួយឱ្យមានកំដៅ និងជួយបញ្ហារលាកតំរងនោម។ សាច់ឈើអាចជួយឱ្យឆ្ងាញ់បាយ ជួយឱ្យមានកំដៅ និងរលាកតំរងនោម។ ប្រេងព្យាបាលស្បែក ជំងឺសន្លាក់ដៃជើង ហឺត និងរលាកទងសួត។ ឫស ព្យាបាលរោគព័ន្ធឆ្លុង (ហើមពេញខ្លួន)។ ខ្លឹម សាច់ឈើ និងឫសអាចប្រើដាំទឹកហូប ឬធ្វើជាថ្នាំគ្រាប់។

# ឯកសារយោង


1. Cho, S.H., Chhang, P. & Kim, Y.D. (2016). A checklist for the seed plants of Cambodia. National Institute of Biological Resources, Ministry of Environment, Incheon, Korea. 272pp.
2. Khou, E.H. (2008). A Field Guide of the Rattans of Cambodia. WWF Greater Mekong – Cambodia Country Programme.
3. Pauline, D.P. (2000). Plants used in Cambodia.
4. Peters, C.M. & Henderson, A. (2014). ប្រព័ន្ធចំណាត់ថ្នាក់ អេកូឡូស៊ី និងការគ្រប់គ្រងប្រភេទផ្តៅនៅកម្ពុជា ឡាវ និងវៀតណាម។ មូលដ្ឋានជីវៈសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព។
5. https://www.iucnredlist.org
6. រុក្ខជាតិឱសថកម្ពុជា ភាគ៤ (២០១០)។ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ (ក្រសួងសុខាភិបាល)
7. រុក្ខជាតិឱសថកម្ពុជា ភាគ៣ ពីអក្សរ ក ដល់ ឪ (២០០៩)។ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ (ក្រសួងសុខាភិបាល)
8. រុក្ខជាតិឱសថកម្ពុជា ភាគ១ ពីអក្សរ ក ដល់ ផ (២០០៨)។ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ (ក្រសួងសុខាភិបាល)
9. រុក្ខជាតិឱសថកម្ពុជា ភាគ២ ពីអក្សរ ផ ដល់ អ (២០០៨)។ មជ្ឈមណ្ឌលជាតិស្រាវជ្រាវវេជ្ជសាស្ត្របូរាណ (ក្រសួងសុខាភិបាល)